ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ តេជោបឹងពោង
# រយៈពេល ៣ឆ្នាំ (២០១៨-២០២០)

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ តេជោបឹងពោង |
| ភូមិ | ៖ មានជ័យ កោះចេក កោះពាមរាំង និងស្ពាន |
| ឃុំ | ៖ កោះចេក |
| ភូមិ | ៖ កំពង់ប្រាសាទ តាហ៊ុយ និងទឹកវិល |
| ឃុំ | ៖ កំពង់ប្រាសាទ |
| ភូមិ | ៖ ខ្ពប សំបូរ និងព្រៃកជ្រៅ |
| ឃុំ | ៖ ព្រៃកសំបូរ និង |
| ភូមិ | ៖ បង្អែក |
| ឃុំ | ៖ ស្វាយភ្លោះ |
| ស្រុក | ៖ ពាមជរ |
| ខេត្ត | ៖ ព្រៃវែង |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងតំបន់ការពារនេសាទសហគមន៍ តេជោបឹងពោង
## រយៈពេល ៣ឆ្នាំ (២០១៨-២០២០)

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ តេជោបឹងពោង |
| ភូមិ | ៖ មានជ័យ កោះចេក កោះពាមរាំង និងស្ពាន |
| ឃុំ | ៖ កោះចេក |
| ភូមិ | ៖ កំពង់ប្រាសាទ តាហ៊ុយ និងទឹកវិល |
| ឃុំ | ៖ កំពង់ប្រាសាទ |
| ភូមិ | ៖ ខ្ពប សំបួរ និងព្រែកជ្រៅ |
| ឃុំ | ៖ ព្រែកសំបួរ និង |
| ភូមិ | ៖ បង្អែក |
| ឃុំ | ៖ ស្វាយភ្លោះ |
| ស្រុក | ៖ ពាមជរ |
| ខេត្ត | ៖ ព្រៃវែង |

# មាតិកា
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១- ស្ថានភាពទូទៅ**...................................................................១

**២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម**...................................................១

ក- ប្រជាពលរដ្ឋ.................................................................................១

ខ- មុខរបរ.......................................................................................២

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**...........២

ក- ទីតាំង.........................................................................................២

ខ- ដែននេសាទ..................................................................................៣

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស...........................................៣

ឃ- ធនធានជលផល.............................................................................៣

**៤- ការធ្វើនេសាទ**...........................................................................៣

ក- អ្នកនេសាទ...................................................................................៣

ខ- ឧបករណ៍នេសាទ.............................................................................៤

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ.......................................................៥

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**.....................................................៦

ក- ទស្សនៈវិស័យ.................................................................................៦

ខ- គោលបំណង..................................................................................៦

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍................................................៦

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ..............................................៦

គ២- ផែនការកែលម្អកន្លែងនេសាទសហគមន៍.........................................៨

គ៣- ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស...........................................៨

គ៤- ផែនការគ្រប់គ្រងព្រៃលិចទឹក......................................................៩

គ៥- ផែនការទប់ស្កាត់បទល្មើសជលផល...............................................៩

គ៦- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ.........១០

គ៧- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល............................................១១

គ៨- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ...........................១៣

គ៩- ផែនការបង្កើតកន្លែងទស្សនាកម្សាន្តក្នុងសហគមន៍នេសាទ (អេកូទេសចរណ៍)................១៤

គ១០- ផែនការបង្កើតក្រុមឥណទាន(សន្សំប្រាក់) ដើម្បីបង្កើនមុខរបរ..................១៥

គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ...............................១៦

គ១២- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ.....................................១៦

គ១៣- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍..................................១៧

ឃ. ផែនការយុទ្ធសាស្ត្រ.............................................................................១៨

តារាងកម្មវិធីការងារ.................................................................................១៩

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទតេជោបឹងពោង បានធ្វើមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៣ ។

សហគមន៍នេសាទតេជោបឹងពោង មានទីតាំងស្ថិតនៅភូមិមានជ័យ កោះចេក កោះពាមរាំង និងភូមិស្ពាន ឃុំកោះចេក ភូមិកំពង់ប្រាសាទ តាហ៊ុយ និងភូមិទឹកវិល ឃុំកំពង់ប្រាសាទ ភូមិខ្ពប សំប្អរ និងភូមិព្រៃកជ្រៅ ឃុំព្រៃកសំប្អរ និងភូមិបង្អែក ឃុំស្វាយភ្លោះ ស្រុកពាមជរ ខេត្តព្រៃវែង។ ដែលមានសមាជិកសហគមន៍នេសាទ សរុបចំនួន ២៥៧នាក់ ប្រុស១៧៥នាក់ ស្រី៨២នាក់ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន២៥៧គ្រួសារ ។ មានគណៈកម្មការចំនួន១១នាក់ ស្រីគ្មាន។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗ របស់ខ្លួនរួមមាន ៖

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- រៀបចំបញ្ជីឈ្មោះសមាជិក និងគណៈកម្មការ សហគមន៍នេសាទ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍និងធ្វើផែនទី
- ចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ផ្សព្វផ្សាយច្បាប់ស្តីពីជលផល
- ទប់ស្កាត់បទល្មើសនេសាទក្នុងកន្លែងនេសាទសហគមន៍
- ការពារព្រៃលិចទឹក
- បង្កើតកន្លែងអភិរក្សត្រីមេពូជ
- ការពារកន្លែងអភិរក្សត្រីមេពូជ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានជលផល
- ទស្សនៈកិច្ចសិក្សា
- ចូលរួមប្រជុំជាមួយភូមិ ឃុំ ស្រុក
- បង្កើតក្រុមមុខរបរ (ចិញ្ចឹមសត្វ ដាំបន្លែ ក្រុមសន្សំឥណទាន)
- ប្រមូលព័ត៌មានទូទៅសំរាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់មាន១៥.៣២៧នាក់ ប្រុស៧.២៨០នាក់ ស្រី៨.០៤៧នាក់ក្នុងនោះ មានចំនួន៣.៤២១គ្រួសារ ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%។

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន៣២ ស្រី១៤នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន១២៥ ស្រី៣៦នាក់ កម្រិតមធ្យមសិក្សាចំនួន៩៧ ស្រី៣១ និងកម្រិតឧត្តមសិក្សាចំនួន៣នាក់ ស្រីចំនួន១នាក់ ។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន១២នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន១នាក់ ស្រីគ្មាន
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន២៤នាក់ ស្រី១៦នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន២ នាក់ ស្រី១នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន៣នាក់ ស្រី២នាក់។

**ខ. មុខរបរ**

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

- ធ្វើនេសាទចំនួន១២៨នាក់ ស្មើនឹង១២៨គ្រួសារ
- ធ្វើស្រែចំនួន១៧៥ គ្រួសារ ទំហំ០,៥-៣ ហិកតា
- ធ្វើចំការចំនួន៤៣គ្រួសារ ទំហំ០,៣-១ ហិកតា
- ដាំបន្លែចំនួន២៥គ្រួសារ ទំហំ០,២-០,៥ ហិកតា
- ធ្វើវារីវប្បកម្មចំនួន៣៤គ្រួសារ ស្រះចំនួន២៦ស្រះ ទំហំ១៥មx១០ម x២ម
- អាងចំនួន៨អាង ទំហំ២,៥មx២,៥ម x១,៥ម
- ជាងផ្ទះចំនួន៤គ្រួសារ
- លក់ដូរចំនួន២១គ្រួសារ
- កម្មករ១៧គ្រួសារ
- មន្ត្រីរាជការ៨គ្រួសារ
- ចិញ្ចឹមសត្វ៤៧គ្រួសារ
- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ១១.៨៣៩.០០០ រៀល ។

## ៣ កន្លែងនេសាទសហគមន៍និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

**ក. ទីតាំង**

កន្លែងនេសាទសហគមន៍គេជោបឹងពោង ត្រូវលុបចេញពីអតីតឡូត៍នេសាទលេខ១៣ ដែននេសាទទឹកសាបក្នុងខេត្តព្រៃវែង មានទំហំ ៣.៤៧០ ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងឃុំស្វាយភ្លោះ
- ខាងត្បូងទល់នឹងឃុំកោះរការ
- ខាងកើតទល់នឹងឃុំកំពង់ប្រាសាទ
- ខាងលិចទល់នឹងឃុំស្វាយភ្លោះ ភូមិបង្អែក កោះចេក និងឃុំព្រៃកសំបូរ ។

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍នេសាទគេជោបឹងពោង មានបឹងចំនួន២បឹង អូរចំនួន១អូរ ប្រឡាយចំនួន១ប្រឡាយ កន្លែងអភិរក្សជលផលចំនួន១ និងដីទំនាបលិចទឹកគឺ៖

- បឹងដាក ទំហំ ២០០ ហិកតា ពេញមួយឆ្នាំ
- បឹងទទឹងថ្ងៃ ទំហំ ៣០ ហិកតា ពេញមួយឆ្នាំ
- អូរស្លាត ទំហំ ២.៤៩៧ម x ១៥ម ពេញមួយឆ្នាំ
- ប្រឡាយកោះចេក ទំហំ ១.៦៣៦ម x ៣០ម ពេញមួយឆ្នាំ (គិតត្រឹមព្រំប្រទល់ទាំងសង្ខាង)
- កន្លែងអភិរក្សជលផលបឹងពោង ទំហំ ៣៥ ហិកតា ពេញមួយឆ្នាំ (គ្រប់គ្រងដោយរដ្ឋបាលជលផល)
- ដីទំនាបលិចទឹកមានទំហំសរុប ៣.១៩៦ ហិកតា។

គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស

បឹងដាក ទំហំ ២០០ ហិកតា ពេញមួយឆ្នាំ ។

ឃ. ធនធានជលផល

- ប្រភេទត្រី ៖

ត្រីរ៉ស់ ត្រីប្រា ត្រីឆ្ពោរ ត្រីឆ្លាំង ត្រីកែស ត្រីក្អែក ត្រីកញ្ចុះ ត្រីលិញ ត្រីរៀល ត្រីក្រាញ់ ត្រីចង្វារ ត្រីផ្ទោង ត្រីស្លូញ ត្រីពោ ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីកន្ទ្រប់ ក្លាំងហាយ ត្រីខ្មាន់ ត្រីក្រឡង់ ត្រីសណ្ដាយ ត្រីអណ្ដែង ត្រីដំរី ត្រីតាអោន ត្រីក្រម៉ម ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ទឹង ត្រីអំពិលទុំ ត្រីគ្រុំ ត្រីផ្កាស្មៅ ត្រីឈ្មៀត ត្រីកញ្ជ្រូក ត្រីបណ្ដូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាក្រហម ត្រីលលកសរ ត្រីឆ្ពិន ត្រីបណ្ដូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ចាញ់ច្រាស ត្រីកំភ្លាញ ត្រីស្លាត ត្រីក្រាយ ត្រីអណ្ដាតឆ្កែ ត្រីកញ្ជនដៃ កំពិស បង្កង។

- ប្រភេទវារីសត្វ ៖

អណ្ដើក ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស(ខ្យងពណ៌លឿង) ក្ដាម អន្ទង់ ខ្ចៅគូចស្រួច ខ្ចៅគូចទាល កង្កែប ឈ្លើង គ្រុំ គ្រុំចំពុះទា លៀស ។ល។

- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ៖

ដើមថ្លើមអណ្ដើក ខ្លបយក្ស(អូយយ៉ាស់/បន្លាយយួន) រាំង ប្របួយមេ ប្របួយឈ្មោល ស្បាត ភ្នំភ្លើង អញ្ចាញ ត្រួស្ដែងក្របី ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្ងាង ខ្នាយមាន់ វល្លិ៍ប្រេង វល្លិ៍ទឹកដោះ វល្លិ៍ត្រដិត វល្លិ៍ដោះគន់ វល្លិ៍ត្រី វល្លិ៍ផ្ទើក អំពាក់ទឹក ស្លាបទា កន្ទាំងហែ ស្មោ ស្លត បន្លាឃ្លេ ថ្នាន់ ស្នួលទឹក ច្រកែង ប្រផេញ ផ្ដៅ ត្នែកព្រាប វល្លិ៍អណ្ដាតត្រកួត ក្រចាប់ សារាយសាប កំប្លោក ចកតូច ចកធំ កំពីងពួយស កំពីងពួយក្រហម ត្រកួន ព្រលិតអាចមន៍មាន់ ព្រលិតដូង រំចង់ ស្ពន់អំបោះ គ្រាវអណ្ដែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំប្លង កក់ជ្រុង កក់ក្ដាម ឈូក ចន្ទល់ភ្នំ(វល្លិ៍ថ្កាល់ត្រី) កញ្ឆែត ស្មៅថ្នក់ទឹក ។ល។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ ៖

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១២៨នាក់ ស្រី៤១នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មាន ចំនួន១.៥៨០នាក់ ស្រី១២១នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៤៥នាក់ស្រី១៧នាក់។

**ខ. ឧបករណ៍នេសាទ ៖**

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ១២៩ | ៣០០ម/គ្រួសារ | ៣៨.៧០០ម៉ែត្រ | ពេញរដូវនេសាទ |
| លបឫស្សី | គ្រឿង | ១៣ | ៨គ្រឿង/គ្រួសារ | ១០៤គ្រឿង | ខែសីហា ដល់ ខែវិច្ឆិកា |
| សំណាញ់ | វង់ | ១០៣ | ១វង់/គ្រួសារ | ១០៣វង់ | ពេញរដូវនេសាទ |
| សន្ទូច | ផ្លែ | ៣២ | ២០០ផ្លែ/គ្រួសារ | ៦.៤០០ផ្លែ | ខែសីហា ដល់ ខែមករា |
| អួនអូសដៃ | វង់ | ១៣ | ៣០ម/១វង់/គ្រួសារ | ៣៩០ម/១៣វង់ | ខែមករា ដល់ ខែមេសា |
| លាន់ | គ្រឿង | ១២ | ៣០គ្រឿង/គ្រួសារ | ៣៦០គ្រឿង | ខែកញ្ញា ដល់ ខែធ្នូ |
| លបត្រីឆ្លាំង(បូម) | គ្រឿង | ៥ | ៣គ្រឿង/គ្រួសារ | ១៥គ្រឿង | ខែកក្កដា ដល់ ខែសីហា |
| លបក្តាម | គ្រឿង | ១៣ | ១០០-៤០០គ្រឿង/គ្រួសារ | ៣.២៥០គ្រឿង | ខែសីហា ដល់ ខែកញ្ញា |
| លបត្រីខ្ចឹង | គ្រឿង | ៤ | ១៧គ្រឿង/គ្រួសារ | ៦៨គ្រឿង | ខែសីហា ដល់ ខែកញ្ញា |
| លបបង្កង | គ្រឿង | ៥ | ៥០-១០០គ្រឿង/គ្រួសារ | ៣៧៥គ្រឿង | ខែសីហា ដល់ ខែតុលា |
| កន្សំ | ដុំ | ៤៦ | ៦ដុំ/គ្រួសារ | ២៧៦ដុំ | ខែកញ្ញា ដល់ ខែវិច្ឆិកា |
| កង្វាត្រីឆ្កួញ | គ្រឿង | ៩ | ១គ្រឿង/គ្រួសារ | ៩គ្រឿង | ខែមករា ដល់ ខែឧសភា |
| ថ្នង | គ្រឿង | ៥ | ១គ្រឿង/គ្រួសារ | ៥គ្រឿង | ខែកញ្ញា ដល់ ខែវិច្ឆិកា |
| ទ្រូ | គ្រឿង | ១២ | ៤គ្រឿង/គ្រួសារ | ៤៨គ្រឿង | ខែមករា ដល់ ខែឧសភា |
| ឡើ | គ្រឿង | ៤ | ៦គ្រឿង/គ្រួសារ | ២៤គ្រឿង | ខែសីហា ដល់ ខែតុលា |
| ឈ្នាងត្រាំ | គ្រឿង | ៨ | ១គ្រឿង/គ្រួសារ | ៨គ្រឿង | ខែមករា ដល់ ខែកុម្ភៈ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៧៧គ្រឿង | ៣០០-៧០០គីឡូក្រាម | ៣,៥-៧សេះ |
| ទូកអុំ និងចែវ | ៨គ្រឿង | ៥០-១០០គីឡូក្រាម | |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ១៤៨ | ៣០០ម-៥០០ម/គ្រួសារ | ៥៩.២០០ម៉ែត្រ | ពេញរដូវនេសាទ |
| លបក្តាម | គ្រឿង | ១៣ | ១០០-២០០គ្រឿង/គ្រួសារ | ១.៩៥០គ្រឿង | ខែសីហា ដល់ ខែកញ្ញា |
| សន្ទូច | ផ្លែ | ៣ | ២០០ផ្លែ/គ្រួសារ | ៦០០ផ្លែ | ខែសីហា ដល់ ខែមករា |
| សំណាញ់ | វង់ | ១០៣ | ១វង់/គ្រួសារ | ១០៣វង់ | ពេញរដូវនេសាទ |
| លាន់ | គ្រឿង | ៤ | ១០០គ្រឿង/គ្រួសារ | ៤០០គ្រឿង | ខែកញ្ញា ដល់ ខែធ្នូ |
| លបត្រីខ្ចឹង | គ្រឿង | ៥ | ៤-៣០គ្រឿង/គ្រួសារ | ៨៥គ្រឿង | ខែសីហា ដល់ ខែកញ្ញា |
| លបបង្កង | គ្រឿង | ៥ | ៥០-១០០គ្រឿង/គ្រួសារ | ៣៧៥គ្រឿង | ខែសីហា ដល់ ខែតុលា |

| | | | | | |
|---|---|---|---|---|---|
| កន្ទុំ | ដុំ | ១៥ | ៦-៣០ដុំ/គ្រួសារ | ២៧០ដុំ | ខែកញ្ញា ដល់ ខែវិច្ឆិកា |
| កង្វាត្រីឆ្លញ | គ្រឿង | ២៧ | ១គ្រឿង/គ្រួសារ | ២៧គ្រឿង | ខែមករា ដល់ ខែឧសភា |
| ថ្នង | គ្រឿង | ១២ | ១គ្រឿង/គ្រួសារ | ១២គ្រឿង | ខែកញ្ញា ដល់ ខែវិច្ឆិកា |
| ទ្រូ | គ្រឿង | ១២ | ៤គ្រឿង/គ្រួសារ | ៤៨គ្រឿង | ខែមករា ដល់ ខែឧសភា |
| ឡើ | គ្រឿង | ៥ | ៦គ្រឿង/គ្រួសារ | ៣០គ្រឿង | ខែសីហា ដល់ ខែតុលា |
| ឈ្នាងត្រាំ | គ្រឿង | ៤ | ១គ្រឿង/គ្រួសារ | ៤គ្រឿង | ខែមករា ដល់ ខែកុម្ភៈ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៣២៥គ្រឿង | ៤០០-១.០០០គីឡូក្រាម | ៦,៥-១០ សេះ |
| ទូកអុំ និងចែវ | ៣៨គ្រឿង | ១០០-២០០គីឡូក្រាម | |

- ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ១៤ | ៣០០-៥០០ម/គ្រួសារ | ៥,៦០០ម៉ែត្រ | ពេញរដូវនេសាទ |
| លបក្តាម | គ្រឿង | ១៣ | ១០០-២០០គ្រឿង/គ្រួសារ | ១.៩៥០គ្រឿង | ខែសីហា ដល់ ខែកញ្ញា |
| សន្ទូច | ផ្លែ | ៣ | ២០០ផ្លែ/គ្រួសារ | ៦០០ផ្លែ | ខែសីហា ដល់ ខែមករា |
| សំណាញ់ | វង់ | ២៧ | ១វង់/គ្រួសារ | ២៧វង់ | ពេញរដូវនេសាទ |
| លាន់ | គ្រឿង | ៤ | ១០០គ្រឿង/គ្រួសារ | ៤០០គ្រឿង | ខែកញ្ញា ដល់ ខែធ្នូ |
| លបត្រីខ្ទីង | គ្រឿង | ៥ | ១៧គ្រឿង/គ្រួសារ | ៨៥គ្រឿង | ខែសីហា ដល់ ខែកញ្ញា |
| លបបង្កង | គ្រឿង | ៥ | ៥០-១០០គ្រឿង/គ្រួសារ | ៣៧៥គ្រឿង | ខែសីហា ដល់ ខែតុលា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៤៥គ្រឿង | ៤០០-១.០០០គីឡូក្រាម | ៦,៥-១០ សេះ |

**គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គ្រួសារអ្នកនេសាទ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចំរុះ | ២០៤ គីឡូក្រាម | ៦៤៤ គីឡូក្រាម | ៨៤៨ គីឡូក្រាម |
| ខ្យង លៀស | ២៥០ គីឡូក្រាម | ៤៥០ គីឡូក្រាម | ៧០០ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

### ក. ទស្សនៈវិស័យ ៖

សហគមន៍នេសាទតេជោបឹងពោង មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

### ខ. គោលបំណង ៖

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុបពីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវគំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (ក្នុងពេលតែមួយ) | |
| -បឹងដាក ២០០ ហិកតា -បឹងទទឹងថ្ងៃ ៣០ ហិកតា (ការធ្វើនេសាទក្នុងបឹងនីមួយៗ) | កក្កដា ដល់ វិច្ឆិកា | មងរាយ | ១០០ម៉ែត្រ | ៥០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ធ្នូ ដល់ មិថុនា | | ៣០០ម៉ែត្រ | ២០គ្រួសារ | |
| | សីហា ដល់ វិច្ឆិកា | លបឬស្សី | ៤គ្រឿង | ១៣គ្រួសារ | |
| | ពេញរដូវនេសាទ | សំណាញ់ | មិនកំណត់ | មិនកំណត់ | |
| | សីហា ដល់ មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៣៥គ្រួសារ | |
| | ពេញរដូវនេសាទ | សន្ទូចបង្កៃ | ៣០ផ្លែ/គ្រួសារ | ៣៥គ្រួសារ | |
| | ពេញរដូវនេសាទ | សន្ទូចបបក់ | មិនកំណត់ | មិនកំណត់ | |
| | ពេញរដូវនេសាទ | សន្ទូចស្ទូច | មិនកំណត់ | មិនកំណត់ | |
| | មករា ដល់ មេសា | អួនអុសដៃ | ៣០ម/គ្រួសារ | ៦គ្រួសារ | |
| | កញ្ញា ដល់ ធ្នូ | លាន់ | ៣០គ្រឿង/គ្រួសារ | ២៥គ្រួសារ | |
| | កញ្ញា ដល់ សីហា | លបត្រីឆ្លាំង(បូម) | ៤គ្រឿង/គ្រួសារ | ៨គ្រួសារ | |
| | សីហា ដល់ កញ្ញា | លបក្តាម | ៥០គ្រឿង/គ្រួសារ | ១៥គ្រួសារ | |
| | សីហា ដល់ កញ្ញា | លបត្រីខ្ទីង | ១០គ្រឿង/គ្រួសារ | ១៥គ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| | សីហា ដល់ តុលា | លបបង្គង | ៥០គ្រឿង/គ្រួសារ | ១៥គ្រួសារ | |
| | កញ្ញា ដល់ វិច្ឆិកា | កន្ទុំ | ១៥ដុំ/គ្រួសារ | ៣០គ្រួសារ | |
| | កញ្ញា ដល់ វិច្ឆិកា | ថ្នង | មិនកំណត់ | មិនកំណត់ | |
| | មករា ដល់ឧសភា | កង្វាត្រីឆ្លូញ | មិនកំណត់ | មិនកំណត់ | |
| | មករា ដល់ ឧសភា | ទ្រូ | ៤គ្រឿង/គ្រួសារ | មិនកំណត់ | |
| | ឧសភាដល់សីហា | ប៉ោង | ២គ្រឿង/គ្រួសារ | មិនកំណត់ | |
| | សីហា ដល់ តុលា | ឡើ | ១០គ្រឿង/គ្រួសារ | មិនកំណត់ | |
| | មករា ដល់ កុម្ភៈ | ឈ្នាងត្រាំ | ១គ្រឿង/គ្រួសារ | មិនកំណត់ | |
| - អូរស្លាត ៣,៧៥ ហិកតា -ប្រឡាយ កោះចេក | ពេញរដូវនេសាទ | មងរាយ | ១០០ម៉ែត្រ | ១០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញរដូវនេសាទ | សំណាញ់ | មិនកំណត់ | មិនកំណត់ | |
| | សីហា ដល់ មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ១០គ្រួសារ | |
| | ពេញរដូវនេសាទ | សន្ទូចបង្កៃ | ២០ផ្លែ/គ្រួសារ | ១០គ្រួសារ | |
| | ពេញរដូវនេសាទ | សន្ទូចបបក់ | មិនកំណត់ | មិនកំណត់ | |
| | ពេញរដូវនេសាទ | សន្ទូចស្ទូច | មិនកំណត់ | មិនកំណត់ | |
| | កញ្ញា ដល់ វិច្ឆិកា | ថ្នង | មិនកំណត់ | មិនកំណត់ | |
| | មករា ដល់ ឧសភា | ទ្រូ | ៤គ្រឿង/គ្រួសារ | មិនកំណត់ | |
| | កញ្ញា ដល់ វិច្ឆិកា | កន្ទុំ | ១០ដុំ/គ្រួសារ | ៥គ្រួសារ | |
| ទំនាបលិចទឹកក្នុងកន្លែងនេសាទសហគមន៍បឹងពោង | កក្កដា ដល់ វិច្ឆិកា | មងរាយ | ១០០ម៉ែត្រ | ៥០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ធ្នូ ដល់ មិថុនា | | ៣០០ម៉ែត្រ | ២០គ្រួសារ | |
| | សីហា ដល់ វិច្ឆិកា | លបឫស្សី | ៤គ្រឿង | ១៣គ្រួសារ | |
| | ពេញរដូវនេសាទ | សំណាញ់ | មិនកំណត់ | មិនកំណត់ | |
| | សីហា ដល់ មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៣៥គ្រួសារ | |
| | ពេញរដូវនេសាទ | សន្ទូចបង្កៃ | ៣០ផ្លែ/គ្រួសារ | ៣៥គ្រួសារ | |
| | ពេញរដូវនេសាទ | សន្ទូចបបក់ | មិនកំណត់ | មិនកំណត់ | |
| | ពេញរដូវនេសាទ | សន្ទូចស្ទូច | មិនកំណត់ | មិនកំណត់ | |
| | កញ្ញា ដល់ ធ្នូ | លាន់ | ៣០គ្រឿង/គ្រួសារ | ២៥គ្រួសារ | |
| | កញ្ញា ដល់ សីហា | លបត្រីឆ្លាំង(បូម) | ៤គ្រឿង/គ្រួសារ | ៨គ្រួសារ | |
| | សីហា ដល់ កញ្ញា | លបក្តាម | ៥០គ្រឿង/គ្រួសារ | ១៥គ្រួសារ | |
| | សីហា ដល់ កញ្ញា | លបត្រីខ្ចឹង | ១០គ្រឿង/គ្រួសារ | ១៥គ្រួសារ | |
| | សីហា ដល់ តុលា | លបបង្គង | ៥០គ្រឿង/គ្រួសារ | ១៥គ្រួសារ | |
| | កញ្ញា ដល់ វិច្ឆិកា | កន្ទុំ | ១៥ដុំ/គ្រួសារ | ៣០គ្រួសារ | |
| | កញ្ញា ដល់ វិច្ឆិកា | ថ្នង | មិនកំណត់ | មិនកំណត់ | |
| | មករា ដល់ឧសភា | កង្វាត្រីឆ្លូញ | មិនកំណត់ | មិនកំណត់ | |
| | មករា ដល់ ឧសភា | ទ្រូ | ៤គ្រឿង/គ្រួសារ | មិនកំណត់ | |
| | ឧសភាដល់សីហា | ប៉ោង | ៤គ្រឿង/គ្រួសារ | មិនកំណត់ | |
| | សីហា ដល់ តុលា | ឡើ | ១០គ្រឿង/គ្រួសារ | មិនកំណត់ | |

### គ.២ ផែនការកែលម្អកន្លែងនេសាទសហគមន៍

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម ៖

| ដែននេសាទ | ទំហំ (ហត) | ទំហំដែលត្រូវកែលម្អ (ហត) | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម - បញ្ចប់ |
|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ | ៣.៤៧០ | ៣.៤៧០ | ប្រជុំផ្សព្វផ្សាយ | ៣០០ | ២០១៨ - ២០១៨ |
| | | | កំណត់ទីតាំងតាមនិយាមកា | ២៥០ | ២០១៨ - ២០១៨ |
| | | | បោះបង្គោលព្រំ ៦បង្គោល | ១.២០០ | ២០១៨ - ២០១៨ |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣៣០ | ២០១៨ - ២០១៨ |
| | | | ពង្រីកព្រំប្រទល់បន្ថែម(បឹងដាក) | ៦០០ | ២០១៨ - ២០១៩ |
| បឹងដាក | ២០០ | ៥០០ម x ២០ម x ២ម = ២០.០០០ម៣ | កំណត់ទីតាំងដាក់ស្តែង | ២៥០ | ២០១៩ - ២០២០ |
| | | | ប្រជុំផ្សព្វផ្សាយជាមួយអ្នកពាក់ព័ន្ធ | ៣០០ | ២០១៩ - ២០២០ |
| | | | បោះបង្គោលព្រំ ៦បង្គោល | ១.២០០ | ២០១៩ - ២០២០ |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣៣០ | ២០១៩ - ២០២០ |
| | | | គ្រឿងចក្រស្តារឡើងវិញ | ២២.៥០០ | ២០១៩ - ២០២០ |
| | | | អាចម៍ដីរៀបចំពង្រៀបមាត់បឹង | | |

### គ.៣ ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស ត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) ត្រូវអភិរក្ស | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងដាក | ៦ (ចំណុចព្រែកដើមសង្កែ) UTM_Indian_1960 X= 523577 Y=1216911 X= 523643 Y=1216411 X= 523531 Y=1216411 X= 523452 Y=1216911 | ត្រីមេពូជ ព្រៃលិចទឹក | ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ (បីលើក) | ៩០០ | ២០១៨ | ២០១៩ |
| | | | បោះបង្គោលព្រំធ្វើពីឈើតំបន់អភិរក្សចំនួន៤បង្គោល | ១.២០០ | ២០១៨ | ២០១៩ |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣៣០ | ២០១៨ | ២០១៩ |
| | | | ដាក់ជំរុំកំប្លោក | ១១៥ | ២០១៨ | ២០១៩ |
| | | | សង់ប៉មយាមការពារកន្លែងអភិរក្សធ្វើពីបេតុងគ្រឿងដែកប្រក់ស្បូវ (៣មx៤មx៨ម) | ៣.០០០ | ២០១៨ | ២០១៩ |
| | | | យាមល្បាតការពារកន្លែងអភិរក្ស | | ២០១៨ | ២០២០ |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំឡើងវិញ ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|---|
| បឹងជាក (ជុំវិញបឹង) | ៤៣,២ | ព្រៃលិចទឹក | ផ្សព្វផ្សាយពីកន្លែងព្រៃលិចទឹកឱ្យបានទូលំទូលាយ | បិទឯកសារ | ៤០០ | ២០១៨ | ២០១៩ |
| | | | | ប្រជុំ | ៨០០ | | |
| | | | បោះបង្គោលព្រំព្រៃលិចទឹកចំនួន ២៦ បង្គោល និងសរសេរស្លាកសញ្ញា | | ៩១០ | ២០១៨ | ២០១៩ |
| | | | ថែរក្សា ការពារ | | | ២០១៨ | ២០២០ |

### គ៥-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំផ្សព្វផ្សាយ<br>-ផ្សព្វផ្សាយតាមមេក្រូ ៣ថ្ងៃ/ឆ្នាំ<br>-ផ្សព្វផ្សាយបិទឯកសារ១ដង/ឆ្នាំ<br>-ប្រជុំផ្សព្វផ្សាយ១ដង/ឆ្នាំ មិថុនា/រៀងរាល់ឆ្នាំ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ និងសារៈសំខាន់នៃធនធានជលផល<br>-មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ<br>-ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ១.៥៦០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ២០១៨ | ២០២០ |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំឆមាស មករា និងមិថុនា/រៀង រាល់ឆ្នាំ | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្របជាក់លាក់ ដើម្បីចុះអនុវត្តន៍ការងារ | ១៦៥ (២ដង/ឆ្នាំ) | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ | ២០១៨ | ២០២០ |
| អនុវត្តន៍ផែនការៈ (រៀបចំកំលាំងចុះបង្ក្រាបដល់ទីកន្លែងដោយទំនាក់ទំនង និងសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ) (៤ដង/ខែ = ១២០/ដង) ជាប្រចាំលើកលែងខែមិថុនា-កក្កដា | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ៨.៦៤០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ | ២០១៨ | ២០២០ |

| | | | | | |
|---|---|---|---|---|---|
| យុទ្ធនាការបង្ក្រាបបទល្មើសនេសាទ | -បទល្មើសនេសាទថយចុះនិងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ១២.៤៥២<br>(២ខែ/ឆ្នាំ) | ក្រុមល្បាតស.ន<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>ប៉ូលិស | មិថុនា-កក្កដា/២០១៨ | មិថុនា-កក្កដា/២០២០ |
| | ប្រេងសាំងនិងប្រេងបាត | ១.២០០<br>(២០លីត្រ/ថ្ងៃ) | | | |
| មធ្យោបាយនិងសម្ភារៈ ៖<br>-សាំង និងប្រេងបាត<br>-អាវភ្លៀង អាវពោង ពិល មួក<br>-កាតទូរស័ព្ទ អាយកូមទាក់ទង<br>-ម៉ាស៊ីនថត កែវយិត | មានលទ្ធភាពចុះល្បាតដោយមានប្រសិទ្ធិភាពខ្ពស់ | ៣.៣៨៦ | សហគមន៍នេសាទ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>អង្គការដៃគូ | ២០១៨ | ២០១៩ |
| ទិញទូកម៉ាស៊ីនថ្មីចំនួន១គ្រឿង | មានមធ្យោបាយចុះល្បាត | ១.៥០០ | សហគមន៍នេសាទ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>អង្គការដៃគូ | ២០១៨ | |

**គ៦-ផែនការប្រជុំប្រចាំខែនិងទិញសម្ភារៈអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ**

ផែនការប្រជុំប្រចាំខែនិងទិញសម្ភារៈអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្តាហ៍ទី៣នៃខែ/រៀងរាល់ត្រីមាស | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការអនុវត្តន៍បន្ត | ៦៦០ | -គណៈកម្មការ<br>-ក្រុមល្បាត | ២០១៨ | ២០២០ |
| ប្រជុំជាមួយអាជ្ញាធរឃុំឬស្ថាប័នពាក់ព័ន្ធ (១០-២០/រៀងរាល់ខែ) | -ទទួលព័ត៌មាននិងផ្តល់របាយការណ៍លទ្ធផលសម្រេចបាន<br>-បញ្ចូលផែនការទៅក្នុងផែនការអភិវឌ្ឍន៍ឃុំនិងផែនការស្ថាប័នពាក់ព័ន្ធ | ៥៤០ | -អាជ្ញាធរឃុំ<br>-គណៈកម្មការ | ២០១៨ | ២០២០ |
| -សម្ភារៈការិយាល័យ ៖<br>-ទិញក្រដាស់ ប៊ិច<br>-ព្រីនឯកសារ<br>-ការទំនាក់ទំនង | មានសម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់ | ៣០០ | គណៈកម្មការ | រយៈពេល៣ឆ្នាំ | |

**គ៧-ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល**

ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាលត្រូវ បានរៀបចំឡើងដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ មានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីច្បាប់<br>-ធនធាន ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន<br>-លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍<br>-ការប្រើប្រាស់និងការទុកដាក់ថ្នាំកសិកម្ម<br>-អំពើហឹង្សាក្នុងគ្រួសារ និង<br>-បទពិសោធន៍ដែលទទួលបាន | -សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តន៍តាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តន៍តាមផែនការនិងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ<br>-ធនត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឱ្យជីវភាពធូរធារនិងគ្មានអំពើហឹង្សាក្នុងគ្រួសារ | ២.៥៨០ | សហគមន៍នេសាទ និងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញធនធាន អង្គការដៃគូ | មេសា-មិថុនា/រៀងរាល់ឆ្នាំ | |
| បិទផ្សាយឯកសារ ១ដង/ឆ្នាំ | | ១៦០ | | ខែមករា/ ២០១៨ | ខែមករា ២០១៩ |
| -ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ<br>-ចែកចាយឯកសារនានា | | ៤៥០ | | មិថុនា ២០១៨ | មិថុនា ២០១៩ |
| ផ្សព្វផ្សាយជ្រើសរើសក្រុមយុវជននិងប្រជាពលរដ្ឋចូលជាសមាជិកស.នគេជោបឹងពោង | មានយុវជននិងប្រជាពលរដ្ឋចូលរួមក្នុងការងារគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ | ១.២០០ | សហគមន៍នេសាទ | ២០១៨ | ២០២០ |
| ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល ៖<br>-របាយការណ៍<br>-កំណត់ហេតុ<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកានិងការគ្រប់គ្រងថវិកាស.ន | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ១.៤០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០១៨ | ២០១៩ |
| វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ | គណៈសហគមន៍នេសាទ (២នាក់) | ៣២៥ | គណៈកម្មការ ស.ន | មីនា/២០១៨ | |

| | | | | |
|---|---|---|---|---|
| វគ្គបណ្តុះបណ្តាលពី ៖ -ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិ -សិទ្ធិជាមូលដ្ឋានលើធនធានធម្មជាតិ | គណៈកម្មការសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ៦៥០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០១៧ |
| វគ្គបណ្តុះបណ្តាលវិធីសាស្ត្រការប្រមូលព័ត៌មាន | គណៈកម្មការសហគមន៍នេសាទ បានយល់ដឹងនិងអាចអនុវត្តន៍ បានក្នុងការងារជាក់ស្តែង | ៤០០ | គណៈកម្មការស.ន | កញ្ញា/២០១៧ |
| វគ្គបណ្តុះបណ្តាលយេនឌ័រ និងការវិភាគយេនឌ័រ | គណៈកម្មការសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ៤០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | មករា/២០១៨ |
| វគ្គបណ្តុះបណ្តាលពីការប្រែប្រួលអាកាសធាតុ | គណៈកម្មការសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ៥០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | មិថុនា/២០១៨ |
| វគ្គបណ្តុះបណ្តាលការរៀបចំផែនការអាជីវកម្ម | គណៈកម្មការសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ៦០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | កក្កដា/២០១៨ |
| វគ្គបណ្តុះបណ្តាលពីការសម្របសម្រួលដោះស្រាយទំនាស់ | គណៈកម្មការសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ៤០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | សីហា/២០១៨ |

គ៨- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការបណ្តុះបណ្តាល | | | | | |
| ចិញ្ចឹម (ត្រី កង្កែប អន្ទង់) | -មានចំណេះដឹង<br>-មានមុខរបរ<br>-បង្កើនប្រាក់ចំណូល | ១.៥០០ | គណៈកម្មការនិងសមាជិកស.ន | កុម្ភៈ/មួយឆ្នាំ (៣ឆ្នាំ) | |
| កែច្នៃផលផលិតផលជលផល | -មានចំណេះដឹង<br>-មានមុខរបរ<br>-បង្កើនប្រាក់ចំណូល | ១.៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| បច្ចេកទេសដាំបន្លែ | -មានចំណេះដឹង<br>-មានមុខរបរ<br>-បង្កើនប្រាក់ចំណូល | ៩០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| បច្ចេកទេសកសិកម្មចម្រុះ និងកសិកម្មបន្ត | -មានចំណេះដឹង<br>-មានមុខរបរ<br>-បង្កើនប្រាក់ចំណូល | ៩០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| កែច្នៃសម្ភារៈប្រើប្រាស់ពីកំប្លោក និងគក់ | -មានចំណេះដឹង<br>-មានមុខរបរ<br>-បង្កើនប្រាក់ចំណូល | ១.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ជំនាញវិជ្ជាជីវៈលើការផ្តល់សេវាទស្សនាកំសាន្ត | -ក្រុមចុងភៅ<br>-ក្រុមផ្ទះស្នាក់នៅ<br>-ក្រុមដឹកជញ្ជូន<br>-ក្រុមធ្វើយានយន្ត<br>-ក្រុមផ្គត់ផ្គង់ផលិតផលកសិកម្ម<br>-ក្រុមរោងលម្ហែ (កញ្ចុះ) | ១.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ទស្សនៈកិច្ចសិក្សា | | ២.៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ផែនការបង្កើតក្រុមមុខរបរ | | | | | |
| ក្រុមកែច្នៃផលិតផលជលផល ដោយផ្តោតលើក្រុមស្ត្រីនិងក្រុមងាយរងគ្រោះ | -គណៈកម្មការនិងសមាជិកសហគមន៍នេសាទបង្កើតឡើងជាក់ស្តែង<br>-មានផលិតផលជលផលផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្តនិងទីផ្សារ<br>-មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ក្រុមដាំបន្លែ | -គណៈកម្មការនិងសមាជិកសហគមន៍នេសាទបង្កើតឡើងជាក់ស្តែង<br>-មានបន្លែផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្ត និងទីផ្សារ<br>-មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |

| | | | | | |
|---|---|---|---|---|---|
| ក្រុមកសិកម្មចម្រុះ និងកសិកម្មបន្ត | -មានក្រុមកសិកម្មចម្រុះ និងបន្ត<br>-មានដំណាំចម្រុះផ្គត់ផ្គង់ដល់កន្លែងកំសាន្តនិងទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៨០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ក្រុមកែច្នៃសម្ភារៈប្រើប្រាស់ពីកំប្លោក និងកក់ | គណៈកម្មការនិងសមាជិកសហគមន៍នេសាទបង្កើតឡើងជាក់ស្តែង<br>-មានសម្ភារៈកែច្នៃផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្ត និងទីផ្សារ<br>-មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |

**គ៩- ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទ (អេកូទេសចរណ៍)**

ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទតេជោបឹងពោង ត្រូវបានរៀបចំឡើងនៅតំបន់បឹងដាក មានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំផ្សព្វផ្សាយ<br>-លើកដំបូង<br>-ដំណើរការរួច | គណៈកម្មការនិងសមាជិកសហគមន៍នេសាទបានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ១.១០០ | សហគមន៍នេសាទ អាជ្ញាធរភូមិ ឃុំនិងស្រុក ជំនាញជលផល ប៉ូលីស និងអង្គការដៃគូ | ២០១៨ | ២០១៩ |
| ទស្សនៈកិច្ចសិក្សា | មានបទពិសោធន៍ស្តីពីការរៀបចំកន្លែងទស្សនាកំសាន្ត (អេកូទេសចរណ៍) | ១.៥៣៥ | សហគមន៍នេសាទ អាជ្ញាធរភូមិ ឃុំនិងស្រុក ជំនាញជលផលនិងអង្គការដៃគូ | ២០១៨ | ២០១៩ |
| រៀបចំទីតាំងទស្សនាកំសាន្ត<br>- ស្លាកសញ្ញាទីតាំងចំនួន១<br>-ដាំដើមឈើចំនួន១០០ដើម<br>-សាងសង់រោងប្រជុំ<br>-សង់រោងលម្ហែចំនួន១២<br>-សាងសង់ស្ពានឫស្សីនិងឈើ<br>-ទូកដឹកជញ្ជូនភ្ញៀវចំនួន៤<br>-ធុងសម្រាមចំនួន១៥<br>-បង្គន់អនាម័យ(បុរស/ស្ត្រី)<br>-បណ្តាញអគ្គីសនី<br>-ផលិតសៀវភៅណែនាំ | ដំណើរការបង្កើតតំបន់ទស្សនាកំសាន្តទទួលបានជោគជ័យ | ១២.៩០០ | សហគមន៍នេសាទ អាជ្ញាធរភូមិ ឃុំនិងស្រុក ជំនាញជលផលនិងអង្គការដៃគូ | ២០១៨ | ២០១៩ |

| | | | | | |
|---|---|---|---|---|---|
| បង្កើតក្រុម | -ក្រុមបដិសណ្ឋារកិច្ច<br>-ក្រុមសេវាម្ហូបអាហារ<br>-ក្រុមរោងសម្រាកលំហែ<br>-ក្រុមផ្ទះស្នាក់នៅ<br>-ក្រុមអាវពោងហែលទឹក<br>-ក្រុមដឹកជញ្ជូន<br>-ក្រុមផ្ញើរយានយន្ត<br>-ក្រុមផ្គត់ផ្គង់ផលិតផលកសិកម្ម<br>-ក្រុមលក់ផលិតផលកែច្នៃ<br>-ក្រុមកសិកម្មបង្ហាញនិងដើម្បីទេសភាព | ១.២០០ | សហគមន៍នេសាទ អាជ្ញាធរភូមិ ឃុំនិង ស្រុក ជំនាញជលផលនិងអង្គការដៃគូ | ២០១៨ | ២០១៩ |
| ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងរបស់ក្រុមមុខរបរ | មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងនៃក្រុមនីមួយៗក្នុងការអនុវត្ត | ៨០០ | គណៈកម្មការ និង សមាជិកស.ន | ២០១៨ | ២០១៩ |
| សន្តិសុខ សណ្តាប់ធ្នាប់និងអនាម័យ | ធានាសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យក្នុងតំបន់ទស្សនាកំសាន្ត | ១.២០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០២០ |

### គ១០- ផែនការបង្កើតក្រុមឥណទាន(សន្សំប្រាក់) ដើម្បីបង្កើនមុខរបរ

ផែនការបង្កើតក្រុមឥណទាន(សន្សំប្រាក់) ដើម្បីបង្កើនមុខរបរ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ ជ្រើសរើសសមាជិកក្រុមសន្សំប្រាក់ | ក្រុមសន្សំប្រាក់ឥណទានសហគមន៍នេសាទគេជោបឹងពោង ត្រូវបានបង្កើតឡើងដោយគណៈកម្មការ និងសមាជិកស.ន | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៨ |
| ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងក្រុមសន្សំប្រាក់ | -មានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមសន្សំប្រាក់<br>-មានដំណើរការល្អ (ខ្ចី សង) | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៨ |
| ផ្តល់ទុនឥណទាន និងប្រមូលប្រាក់សន្សំ | មានទុនសម្រាប់កម្ចីនិងការចាប់ផ្តើមមុខរបរ | ២.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៨ |
| ប្រជុំប្រចាំខែ | -របាយការណ៍សាច់ប្រាក់<br>-ការរីកចម្រើននូវមុខរបរ | ២៧០ | ក្រុមសន្សំប្រាក់ | ២០១៨ | ២០២០ |

**គ១១-ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ**

ផែនការសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ប៉ាន់ស្មានតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីតាមស្រះ (២៦គ្រួសារ) | ២៣សx១០មx២០មx២ម | ប្រា ឆ្ពិន កាប អណ្តែង | ១០.០០០ កូន/ឆ្នាំ | ៦.៨២៦ | ២០១៨ | ២០២០ |
| ចិញ្ចឹមកង្កែប អន្ទង់ តាមអាង(៨គ្រួសារ) | ៤អx២មx១,៥មx១,២ម | អន្ទង់ | | ៥០០ | ២០១៨ | ២០២០ |
| | ៤អx២មx១,៥មx១,២ម | កង្កែប | | ៥០០ | ២០១៨ | ២០២០ |

**គ១២- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ**

ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទនៅចំណុចដើមអំពិលបារាំង មាត់បឹងដាកខាងលិច ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៦មx៨ម ធ្វើពីគ្រឿងឈើ ប្រក់ស័ង្កសី ដោយមានបង្គន់ អនាម័យ | -សហគមន៍នេសាទមានការិយាល័យសម្រាប់ធ្វើការ -មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រង កន្លែងនេសាទសហគមន៍ | ៦.៥០០ | គណៈកម្មការ សមាជិកស.ន ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០១៨ | ២០១៩ |
| បណ្តាញអគ្គីសនី | មានថាមពលអគ្គីសនីសម្រាប់ ស.នធ្វើការងារ | ២៥០ | | ២០១៨ | ២០១៩ |
| សម្ភារៈសហគមន៍នេសាទ ៖ (តុទូ ក្តារខៀន កៅអី កំព្យូទ័រ ព្រីនធើ) | មានសម្ភារៈសម្រាប់ស.នធ្វើការ | ១.១៥០ | | ២០១៨ | ២០១៩ |

**គ១៣-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍**

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ ប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូល ដុល្លា | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាព សហគមន៍នេសាទ | -ផ្សព្វផ្សាយការចូលជាសមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន ២០០រៀល/ម្នាក់ | ២០១៨ | ២០២០ | ១២,៨៥ | ២០០រៀល/នាក់ (២៥៧នាក់) |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំសមាជិកស.ន ៥០០ រៀល/ម្នាក់ | ២០១៨ | ២០២០ | ៩៦,៣៧ | ៥០០រៀល/ម្នាក់ (២៥៧នាក់) |
| កម្រៃអ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ | ប្រមូលប្រាក់កម្រៃពី អ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ ១០០.០០០រៀល/នាក់/ ឆ្នាំ ក្នុងនោះចំនួន១០% បានបង់ប្រាក់កម្រៃ | ២០១៨ | ២០២០ | ៦.០៧៥ | កម្រៃប៉ាន់ប្រមាណ៥% នៃអ្នកនេសាទមិនមែនជាសមាជិកចំនួន១.៥៨០នាក់ និងអ្នកខាងក្រៅ ៤៥នាក់ សរុប១.៦២៥នាក់ បានបង់ចំនួន ៨១នាក់ |
| សរសេរគម្រោងស្នើសុំថវិកាពី ៖<br>-រាជរដ្ឋាភិបាល<br>-សប្បុរសជន<br>-អង្គការដៃគូរពាក់ព័ន្ធ | ទំនាក់ទំនងជាមួយ ៖<br>-មន្ទីរពាក់ព័ន្ធជុំវិញខេត្ត<br>-អង្គការដៃគូពាក់ព័ន្ធ<br>-សប្បុរសជន<br>-សរសេរគម្រោងស្នើសុំ<br>-តាមដាននិងវាយតម្លៃ | ២០១៨ | ២០២០ | ១១៨.៥៩០ | សរសេរគម្រោងស្នើសុំថវិកាចំណាយ ៥០០ដុល្លា |
| សរុប | | | | ១២៤.៧៧៤ | |

### ឃ. ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តន៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការ រួមមាន សមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗ ជាពិសេសម្ចាស់បញ្ញានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង និងបច្ចេកទេសជលផល ដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែង អភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្របច្ចេកទេសនិងថវិការសម្រាប់ដំណើរការអនុវត្តន៍ផែនការ
- រៀបចំផែនការអនុវត្តន៍តាមដំណាក់កាលនីមួយៗ ដោយជាក់លាក់និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលនិងស្ថាប័នពាក់ព័ន្ធ ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទនិងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- ធ្វើសមាហរណកម្មបញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ
- រៀបចំធ្វើស្នាក់ការសហគមន៍នេសាទចំនួនមួយខ្នងនិងទិញទូកម៉ាស៊ីនចំនួន១គ្រឿងសម្រាប់គ្រប់គ្រងនិងថែរក្សាការពារកន្លែងនេសាទសហគមន៍ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍គេជោបឹងពោង រយៈពេល ៣ ឆ្នាំ (២០១៨ ដល់ ២០២០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ធ្វើនេសាទ | -មាននិរន្តរភាពធនធាន<br>-បង្កើនប្រាក់ចំណូល | | សមាជិកនិងគណៈកម្មការ | ២០១៨ | ២០២០ | |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | -កំណត់ទីតាំងជាក់ស្ដែងតាមនិយាមកា<br>-ប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ<br>-បោះបង្គោលព្រំនិងសរសេរស្លាកសញ្ញា<br>-ពង្រីកព្រំប្រទល់សហគមន៍នេសាទ | -ស្គាល់ព្រំប្រទល់ច្បាស់លាស់<br>-ពង្រីកព្រំប្រទល់បន្ថែមធំជាងមុន<br>-ត្រីមានទីជម្រក<br>-ព្រៃលិចទឹកបានគង់វង្ស<br>-ត្រីកើន<br>-មានទឹកប្រើប្រាស់ | ២.៦៨០ | - ស.ន.ត.ប.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៨ | |
| | -ប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ<br>-កំណត់ទីតាំងជាក់ស្ដែង<br>-សាងសង់ទំនប់បង្ហៀរធ្វើពីបេតុង<br>-រៀបចំទ្វារបិទបើកទឹកធ្វើពីឈើគគី<br>-គ្រឿងចក្រស្ដារឡើងវិញ | | ២៤.៥៨០ | | ២០១៨ | ២០២០ | |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-កំណត់ទីតាំងតាមនិយាមកា<br>-បោះបង្គោលព្រំនិងដាក់ស្លាកសញ្ញា<br>-សាងសង់ប៉មយាម | -មានទីជម្រកនិងមានត្រីមេពូជ<br>-ត្រីកើនឡើងវិញ<br>-ព្រៃលិចទឹកកើនឡើងវិញ<br>-ធនធានជលផលបានគង់វង្ស | ៥.៥៤៥ | - ស.ន.ត.ប.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| | យាមល្បាតការពារកន្លែងអភិរក្ស | | | | ២០១៨ | ២០២០ | |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-កំណត់ទីតាំងជាក់ស្ដែង<br>-បោះបង្គោលព្រំព្រៃលិចទឹកនិងសរសេរស្លាកសញ្ញា | -ព្រៃលិចទឹកបានគង់វង្ស<br>-ជាជម្រកត្រី | ២.១១០ | - ស.ន.ត.ប.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| | ថែរក្សា ការពារ | | | | ២០១៨ | ២០២០ | |
| គ៥.ផែនការទប់ស្កាត់បទល្មើសជលផល | - ផ្សព្វផ្សាយៈមេក្រូ ប្រជុំ បិទ ចែកឯកសារ<br>-ប្រជុំរៀបចំផែនការល្បាត<br>-អនុវត្តន៍ផែនការចុះបង្ក្រាបជាក់ស្ដែង<br>-យុទ្ធនាការបង្ក្រាបបទល្មើសជលផល | -បទល្មើសថយចុះ<br>-ធនធានព្រៃលិចទឹកនិងត្រីកើនឡើងវិញ<br>-ផលចាប់ត្រីបានច្រើន | ២២.៨១៧ | - ស.ន.ត.ប.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០២០ | |
| | ទិញមធ្យោបាយនិងសម្ភារៈប្រើប្រាស់ | មានមធ្យោបាយ សម្ភារៈល្បាត | ៦.០៤៦ | | ២០១៨ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៦.ផែនការប្រជុំប្រចាំខែ និងទិញសម្ភារៈអនុវត្តន៍ការងារគណៈកម្មការស.ន | -ប្រជុំគណៈកម្មការស.ន<br>-ប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ<br>-ទិញសម្ភារៈការិយាល័យ | -របាយការណ៍លទ្ធផលសម្រេចបានប្រចាំខែ<br>-មានសម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់ | ១.៥០០ | - ស.ន.ត.ប.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០២០ | |
| គ៧.ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល | ផ្សព្វផ្សាយ (ប្រជុំ ចិទផ្សាយ ចែកឯកសារ)៖ ច្បាប់ជលផល ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន, លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង, ផែនការគ្រប់គ្រងស.ន, ការប្រើប្រាស់ថ្នាំកសិកម្ម និងបទពិសោធន៍ទទួលបាន | -គណៈកម្មការនិងសមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋមានចំណេះដឹងនិងបទពិសោធន៍<br>-អាចយកទៅអនុវត្តន៍បាន | ៣.១៩០ | - ស.ន.ត.ប.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០២០ | |
| | ផ្សព្វផ្សាយជ្រើសរើសក្រុមយុវជន និងប្រជាពលរដ្ឋចូល ជាសមាជិកសហគមន៍នេសាទតេជោបឹងពោង | | ១.២០០ | | ២០១៨ | ២០១៨ | |
| | វគ្គបណ្តុះបណ្តាលស្តីពី ៖<br>-ការរៀបចំរបាយការណ៍ កំណត់ហេតុ<br>-គម្រោងស្នើសុំនិងការគ្រប់គ្រងថវិកា<br>-ការប្រើប្រាស់កំព្យូទ័រ<br>-ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិ<br>-សិទ្ធិជាមូលដ្ឋានលើធនធានធម្មជាតិ<br>-វិធីសាស្រ្តប្រមូលព័ត៌មាន<br>-យេនឌ័រនិងការវិភាគយេនឌ័រ<br>-ការប្រែប្រួលអាកាសធាតុ<br>-ការរៀបចំផែនការអាជីវកម្ម<br>-សម្របសម្រួលនិងដោះស្រាយទំនាស់ | | ៤.៦៧៥ | | ២០១៨ | ២០១៩ | |
| គ៨.ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍ | វគ្គបណ្តុះបណ្តាលស្តីពី៖<br>-បច្ចេកទេសចិញ្ចឹម(ត្រី កង្កែប អន្ទង់) | -មានចំណេះដឹងនិងបច្ចេកទេសលើមុខរបរ | ៩.៣០០ | - ស.ន.ត.ប.ព<br>- រាជរដ្ឋាភិបាល | ២០១៨ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | -បច្ចេកទេសកែច្នៃផលនេសាទ<br>-បច្ចេកទេសដាំបន្លែ<br>-បច្ចេកទេសកសិកម្មចម្រុះនិងបន្ត<br>-បច្ចេកទេសកែច្នៃសម្ភារៈធ្វើពីកំប្លោកកក់<br>-ជំនាញវិជ្ជាជីវៈលើការផ្តល់សេវាកម្សាន្ត<br>-ទស្សនៈកិច្ចសិក្សា | -អាចអនុវត្តន៍បានក្នុងការប្រកបមុខរបរ<br>-បន្ថែមប្រាក់ចំណូលដើម្បីលើកកម្ពស់កម្រិតជីវភាព | | - អង្គការដៃគូ<br>- សប្បុរសជន | | | |
| | បង្កើតក្រុមមុខរបរ ៖<br>-ក្រុមកែច្នៃផលនេសាទ<br>-ក្រុមដាំបន្លែ<br>-ក្រុមកសិកម្មចម្រុះនិងបន្ត<br>-ក្រុមកែច្នៃសម្ភារៈប្រើប្រាស់ធ្វើពីកំប្លោកនិងកក់ | -មានក្រុមមុខរបរកើតឡើង<br>-មានផលិតផលផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | ២.៣០០ | - ស.ន.ត.ប.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| គ៩.ផែនការបង្កើតកន្លែងកម្សាន្តក្នុងសហគមន៍នេសាទ (អេកូទេសចរណ៍) | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-ទស្សនៈកិច្ចសិក្សា<br>-រៀបចំទីតាំងទស្សនាកម្សាន្ត<br>-បង្កើតក្រុមមុខរបរ<br>-ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងនៃក្រុម<br>-សន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ | -ប្រភពចំណូលដល់សហគមន៍នេសាទ<br>-បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ<br>-មានភ្ញៀវមកកម្សាន្ត | ១៨.៧៣៥ | - ស.ន.ត.ប.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| គ១០.ផែនការបង្កើតក្រុមឥណទាន(សន្សំប្រាក់) ដើម្បីបង្កើនមុខរបរ | -ផ្សព្វផ្សាយជ្រើសរើសអ្នកស្ម័គ្រចិត្តបង្កើតក្រុមឥណទាន(សន្សំប្រាក់)<br>-រៀបចំរចនាសម្ព័ន្ធនៃក្រុមឥណទាន<br>-ប្រជុំរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង<br>-ផ្តល់ទុនឥណទាននិងប្រមូលប្រាក់សន្សំ | -មានក្រុមឥណទាន(សន្សំប្រាក់)<br>-មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមឥណទាន<br>-មានដំណើរការល្អ(ខ្ចី សង)<br>-របាយការណ៍ឥណទាន<br>-ការរីកចម្រើននូវមុខរបរ | ៣.២៧០ | - ស.ន.ត.ប.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៨ | |
| | ប្រជុំប្រចាំខែនិងរបាយការណ៍ឥណទាន | | | | ២០១៨ | ២០២០ | |
| គ១១.ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ | -ចិញ្ចឹមត្រីតាមស្រះ<br>-ចិញ្ចឹមកង្កែប អន្ទង់តាមអាងឬតង់ | -បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ | ៧.៨២៦ | - ស.ន.ត.ប.ព<br>- រាជរដ្ឋាភិបាល | ២០១៨ | ២០២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| នេសាទ | -ទិញកូនត្រី និងពូជកង្កែប អន្ទង់ | -មានផលិតផលត្រី កង្កែប អន្ទង់ផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | | - អង្គការដៃគូ<br>- សប្បុរសជន | | | |
| គ១២.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទតេជោបឹងពោង | -ប្រជុំជាមួយអ្នកពាក់ព័ន្ធ<br>-សាងសង់ស្នាក់ការ<br>-រៀបចំបណ្តាញអគ្គីសនី<br>-ទិញសម្ភារៈ | -ទទួលបានការចូលរួម ការគាំទ្រ<br>-សហគមន៍នេសាទមានការិយាល័យសម្រាប់ធ្វើការ<br>-មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងនេសាទសហគមន៍<br>-មានថាមពលអគ្គីសនីសម្រាប់ស.នធ្វើការងារ<br>-មានសម្ភារៈប្រើប្រាស់<br>-សម្រេចបានសកម្មភាពការងារ | ៧.៩០០ | - ស.ន.ត.ប.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| គ១៣.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | -ប្រមូលភាគទានសមាជិកភាព<br>- ភាគទានប្រចាំឆ្នាំ<br>- ភាគទានពីអ្នកមិនមែនសមាជិក<br>សរសេរគម្រោងស្នើសុំពី ៖ ស្ថាប័នពាក់ព័ន្ធ (មន្ទីរជុំវិញខេត្ត) អង្គការដៃគូនានា និងសប្បុរសជន | មានថវិកាអនុវត្តន៍សកម្មភាពគ្រប់គ្រងសហគមន៍នេសាទ | ១២៤.៧៧៤ | - រាជរដ្ឋាភិបាល<br>- អង្គការដៃគូនានា<br>- សប្បុរសជន | ២០១៨ | ២០២០ | សរសេរគម្រោងចំណាយ ៥០០ |

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៨ | | | | | | | | | | | | ២០១៩ | | | ២០២០ | | |
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | .... | ធ្នូ | មករា | ... | ធ្នូ |
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | → | → | → | → | → | → | → | → | → | → | → | → | | | | | | |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | | |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | | |
| គ៥.ផែនការទប់ស្កាត់បទល្មើសជលផល | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | | |
| គ៦.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារការិយាល័យ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ៧.ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល | → | → | → | → | → | → | → | → | → | → | → | → | | | | | | |
| គ៨.ផែនការបង្កើតមុខរបរសមាជិកសហគមន៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | | |
| គ៩.ផែនការបង្កើតកន្លែងកម្សាន្តក្នុងសហគមន៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | | |
| គ១០.ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ | → | → | → | → | → | → | → | → | → | → | → | → | | | | | | |
| គ១១.ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ១២.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | | |
| គ១៣.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |

លេខ.....549/2017...

បានឃើញនិងគោរពជូន

លោកនាយសង្កាត់រដ្ឋបាលជលផលពាមជរ

«ដើម្បីជូនពិនិត្យនិងសម្រួល»

សូមគោរពជូន

លោកមេឃុំពាក់ព័ន្ធ

«ដើម្បីជូនពិនិត្យនិងសម្រួល»

ថ្ងៃ.......ខែ......ឆ្នាំ......សក ព.ស.25..

ពាមជរ,ថ្ងៃទី.....25.....ខែ......គ.ស...2017

ប្រធានគណៈកម្មការសហគមន៍នេសាទតេជោបឹងពោង

ឈៀ យោន

លេខ.....549/2017...

ថ្ងៃ.......ខែ......ឆ្នាំ......សក ព.ស.2561 ថ្ងៃ.......ខែ......ឆ្នាំ......សក ព.ស.2561

កំពង់ប្រាសាទ,ថ្ងៃទី....29.....ខែ......គ.ស....2017

មេឃុំកំពង់ប្រាសាទ

លន់_ភុល

ពាមជរ,ថ្ងៃទី....29.....ខែ......គ.ស....2017

មេឃុំកោះចេក

អ៊ឹម គាវី

បានឃើញនិងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលស្ទឹងស្លូត

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ......................ខែ............ឆ្នាំ........ .......ស័ក ព.ស..........

ពាមជរ ថ្ងៃទី 04 ខែ 05 គ.ស 2018

**នាយសង្កាត់រដ្ឋបាលជលផលពាមជរ**

លេខ..........

បានឃើញនិងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

«ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ»

ថ្ងៃ..........ខែ..........ឆ្នាំ..........ស័ក ព.ស ២៥៦២

ព្រៃវែង ថ្ងៃទី ២៤ ខែ ឧសភា គ.ស ២០១៨

**ប្រធាន**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង**

**អ៊ុក សំណាង**

លេខ 241/18

ថ្ងៃ..........ខែ..........ឆ្នាំ ច .......ស័ក ព.ស 2561

ស្វាយឆ្លាះ ថ្ងៃទី 26 ខែ 4 គ.ស 2017

**មេឃុំស្វាយឆ្លាះ**

គ្រី_សាន

លេខ 221/18

បានឃើញនិងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង

«ដើម្បីជូនពិនិត្យនិងសម្រួល»

ថ្ងៃ..........ខែ..........ឆ្នាំ ច ........ស័ក ព.ស 2562

ព្រៃវែង ថ្ងៃទី 22 ខែ 5 គ.ស 2018

**នាយខណ្ឌរដ្ឋបាលជលផលព្រៃវែង**

**អូន_ស៊ីណាត**

លេខ ២៧៦៣ ជផ

បានឃើញនិងឯកភាព

ថ្ងៃ..........ខែ..........ឆ្នាំ..........ស័ក ព.ស.........

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា គ.ស ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

លេខ..........

ថ្ងៃ..........ខែ..........ឆ្នាំ ច .......ស័ក ព.ស 2561

ព្រែកសំបួរ ថ្ងៃទី 22 ខែ 4 គ.ស 2018

**មេឃុំព្រែកសំបួរ**

សុផល

លេខ 07/018

បានឃើញនិងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលព្រៃវែង

«ដើម្បីជូនពិនិត្យនិងសម្រួល»

ថ្ងៃ......................ខែ............ឆ្នាំ........ .......ស័ក ព.ស..........

ថ្ងៃទី 04 ខែ 05 គ.ស 2018

**នាយផ្នែករដ្ឋបាលជលផលស្ទឹងស្លូត**